# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**
លេខ ៣៩៥ រប.៩៧

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

## ឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សូមជ្រាប។**

**កម្មវត្ថុ:** ការប្រគល់ឈ្មោះ ចៅ សុខុន ហៅ វ៉ែវណ្ណនី មកតុលាការក្រុងភ្នំពេញ ។

**យោង:** ដីកាស្វែងរកចាប់ខ្លួន ចៅ សុខុន ហៅ វ៉ែវណ្ណនី លេខ ១៥៩៧ តព្រ ចុះថ្ងៃទី១១-០៤-៩៧ ។

-លិខិតរបស់មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេសលេខ ៣៨/៩៧ អហ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ១៩៩៧ ។

ខ្ញុំសូមជម្រាបឯកឧត្តមសហរដ្ឋមន្ត្រីជ្រាបថា តាមសេចក្តីរាយការណ៍របស់តុលាការនឹងអយ្យការ ព្រឹកមិញនេះ ថ្ងៃទី២២-០៤-៩៧ ឈ្មោះចៅ សុខុន ត្រូវបានប្រគល់ខ្លួនឱ្យទៅកងរាជអាវុធហត្ថដែលជាមន្ត្រីយុត្តិធម៌ ព្រឹកមិញនេះ។ ប៉ុន្តែលោកឧត្តមសេនីយ៍ វណ្ណ មុនី មេបញ្ជាការរងនៃកងរាជអាវុធហត្ថ ដោយសំអាងលើការណែនាំពីរដ្ឋលេខាធិការក្រសួងយុត្តិធម៌ មិនអោយប្រគល់ខ្លួនជននេះទៅតុលាការទេ ដោយថាសហរដ្ឋមន្ត្រីក្រសួងការពារជាតិមិនទាន់បានអនុញ្ញាតឱ្យធ្វើការចោទប្រកាន់ បានត្រឹមតែប្រគល់ភារកិច្ចឱ្យអគ្គសេនាធិការកងយោធពលខេមរភូមិន្ទដោះស្រាយតែប៉ុណ្ណោះ ។

ខ្ញុំសូមជម្រាបឯកឧត្តមសហរដ្ឋមន្ត្រីជ្រាបថា យោធិនមិនស្ថិតនៅក្រោមមាត្រា៥១ នៃសហលក្ខន្តិកៈនៃមន្ត្រីរាជការស៊ីវិលទេ។ ហេតុនេះតាមផ្លូវច្បាប់ការចោទប្រកាន់ ឬការចាប់ខ្លួនយោធិនណាមួយដែលបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌសាមញ្ញ ច្បាប់មិនទាមទារឱ្យសុំការអនុញ្ញាតពីក្រសួងគ្រប់គ្រងជាមុនសិនទេ ។ ការដែលក្រសួងយុត្តិធម៌បានសុំមកក្រសួងការពារជាតិរហូតមកដល់ពេលនេះ គឺជាការជៀសវាងកុំឱ្យមានការផ្ទុះអាវុធរវាងសាមីខ្លួន ឬបក្សពួកប្រឆាំងនឹងការអនុវត្តច្បាប់តែប៉ុណ្ណោះ ។

ខ្ញុំសុំបញ្ជាក់មួយចំណុចទៀតថា តាមផ្លូវច្បាប់ការស៊ើបអង្កេតរឿងព្រហ្មទណ្ឌជាសមត្ថកិច្ចរបស់តុលាការ មិនមែនសមត្ថកិច្ចរបស់អំណាចនីតិបញ្ញត្តិ ឬអំណាចនីតិប្រតិបត្តិឡើយ។ ការចោទប្រកាន់មិនមែនមានន័យថាចាត់ទុកសាមីខ្លួនជាជនមានកំហុសនឹងមានទោស វីសម្រាប់បើកផ្លូវឱ្យតុលាការធ្វើការស៊ើបអង្កេតនោះឯង ។ ហេតុនេះបើយើងជាអង្គការនីតិប្រតិបត្តិធ្វើការស៊ើបអង្កេតលើរឿងព្រហ្មទណ្ឌ គឺយើងប្រព្រឹត្តិជាន់ទៅលើសមត្ថកិច្ចរបស់តុលាការ

ខ្ញុំសុំជម្រាបជូនជ្រាបនូវគោលការណ៍នៃច្បាប់មួយទៀត បើយើងមិនព្រមអនុញ្ញាតឱ្យរយ្យការ ធ្វើការចោទប្រកាន់ ឬមិនអនុញ្ញាតឱ្យចាប់ខ្លួនតាមដីកាចាប់ខ្លួនរបស់តុលាការទេ នេះគឺជាអំពើរាំងការដំណើរការរបស់តុលាការ ហើយតុលាការមានសិទ្ធិចោទប្រកាន់ និងផ្តន្ទាទោសដាក់គុកអ្នកបញ្ជាឱ្យរាំង និងអ្នករាំងពី ៣ខែ ដល់ ២ ឆ្នាំ តាមច្បាប់ជាធរមាន ។

តាមព័ត៌មានដែលក្រសួងយុត្តិធម៌ទទួលបាន បន្ទាប់ពីការសុំចោទប្រកាន់ តុលាការបានចេញដីកាឱ្យស្វែងរកចាប់ខ្លួនជនល្មើសរួចអស់ហើយ ។

ខ្ញុំយល់ឃើញថាក្រសួងការពារជាតិមិនគួរធ្វើអ្វីប្រឆាំងនឹងច្បាប់ជាធរមាន គួរតែប្រគល់សាមីជនជូនទៅតុលាការ បើពុំនោះទេយើងនឹងជួបបញ្ហាជៀសមិនរួចចំពោះមុខច្បាប់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

ចម្លងជូន

-សម្តេចនាយករដ្ឋមន្ត្រីទី ១

-សម្តេចនាយករដ្ឋមន្ត្រីទី ២

-លេខាធិការដ្ឋានរដ្ឋសភា

-តុលាការ និងអយ្យការ

-កាលប្បវត្តិ